មជ្ឈមណ្ឌលឯកសារកម្ពុជា

# របាយការណ៍
# ស្តីពីទីតាំងប្រល័យពូជសាសន៍
# នៅស្រុកព្រៃវែង និងស្រុកពារាំង ខេត្តព្រៃវែង
# កាលពីថ្ងៃទី១ដល់ថ្ងៃទី៤ ខែឧសភា ឆ្នាំ២០០២

ដោយៈ ផេង ពង្សរ៉ាស៊ី

បេសកកម្មស្រាវជ្រាវ និងធ្វើផែនទីរណ្តៅសាកសពមួយបានត្រូវអនុវត្តឡើង បន្ទាប់ពីមានការយល់ព្រមពីនាយកមជ្ឈមណ្ឌលឯកសារកម្ពុជា ។ មានស្រុកចំនួនពីរក្នុងចំណោមស្រុកទាំង១២នៃខេត្តព្រៃវែង ត្រូវស្ថិតក្នុងការស្រាវជ្រាវរបស់ក្រុមខ្ញុំ ។ ស្រុកទាំងពីរនោះគឺ ស្រុកព្រៃវែង និងស្រុកពារាំង ។

## ស្រុកព្រៃវែង

ខ្ញុំបានធ្វើដំណើរបន្តពីទីរួមខេត្តព្រៃវែងឆ្ពោះទៅកាន់ផ្លូវបំបែកត្រង់ទីប្រជុំជនស្វាយអន្ទរ រួចធ្វើដំណើរតាមផ្លូវលំមួយខ្សែឆ្ពោះទៅកាន់ទីរួមស្រុកព្រៃវែង និងស្រុកកំចាយមារ ។ រយៈពេលជាងមួយម៉ោងក្រោយមកខ្ញុំបានធ្វើដំណើរមកដល់ផ្លូវបំបែកមួយទៀតឆ្ពោះទៅកាន់ឃុំពានរោងស្រុកព្រៃវែង ។ នៅតាមផ្លូវខ្ញុំបានសាកសួរពត៌មានខ្លះៗស្តីពីគោលដៅនៃការស្រាវជ្រាវ ពីប្រជាពលរដ្ឋដែលរស់នៅតាមដងផ្លូវ ។ ជាលទ្ធផលគោលដៅនេះបានត្រូវបង្ហាញ ។ ឯដំណឹងអសន្តិសុខតាមផ្លូវបានត្រូវគំរាមកំហែងដល់អារម្មណ៍របស់ខ្ញុំ និងក្រុមស្រាវជ្រាវទាំងមូល ។ ក្នុងបំណងល្អពីប្រធានឃុំពានរោង, ប្រជាពលរដ្ឋនៅម្តុំទីប្រជុំជនពានរោង និងអ្នកឯទៀត ក្រុមស្រាវជ្រាវយើងបានត្រូវហាមឃាត់ដំណើរឆ្ពោះទៅកាន់ភូមិជ្រៃលើង ព្រោះក្នុងរយៈពេលកន្លងមកមានប្រជាពលរដ្ឋមួយចំនួនបានទទួលរងនូវអំពើប្លន់ប្រដាប់អាវុធជាញឹកញាប់ពីសំណាក់ចោរប្លន់ក្នុងស្រុក ។ ពុំដែលប្រទះឃើញអ្នកមកពីភ្នំពេញឬអ្នកចម្ងៃកណាម្នាក់ចូលមកស្នាក់នៅក្នុងភូមិនេះឡើយ ។ ក្នុងចម្ងាយដី១៤គីឡូម៉ែត្រកន្លះពីផ្លូវជាតិ ខ្ញុំបានធ្វើដំណើរតាមផ្លូវក្រហែងក្រហូងមួយខ្សែឆ្ពោះទៅកាន់ភូមិជ្រៃលើងទាំងបារម្ភ ។

«រឿងរ៉ាវដែលកប់បាត់អស់ជាង២០ឆ្នាំហើយនោះបានត្រូវគាស់សើរើឡើងវិញហើយ» នេះជាសម្តីរបស់ប្រធានភូមិជ្រៃលើងដែលបាននិយាយនៅក្នុងខ្ទមមុខផ្ទះរបស់គាត់កាលពីរសៀលម៉ោងជាង៣ ក្នុងខណៈពេលដែលគាត់បានជជែកលេងជាមួយក្រុមស្រាវជ្រាវនៃមជ្ឈមណ្ឌលឯកសារកម្ពុជា ។ ប្រធានភូមិរូបនោះឈ្មោះយ៉ុន ហ៊ាង អាយុ៥០ឆ្នាំ ។ «ខ្ញុំចង់បកស្រាយរឿងនេះ(ប្រល័យពូជសាសន៍) និងចង់ចងក្រងជាប្រវត្តិសាស្ត្រដែរ

ប៉ុន្តែគ្មាននរណាមកស្រាវជ្រាវសោះ», មួយឃ្លានេះក៏ជាសម្តីផ្ទាល់របស់ប្រធានភូមិឈ្មោះ យ៉ុន ហ៊ាងដែរ ។ ស្ថិតក្នុងសណ្ឋានចិត្តចង់បង្ហាញប្រាប់ពីអំពើទាំងឡាយដែលទាក់ទងនឹងរបបប្រល័យពូជសាសន៍ ហ៊ាងបានទំលាក់ចោលអស់នូវប្រដាប់ប្រដាធ្វើស្រែមួយចំនួន ហើយត្រឡប់មកអន្តុយជជែកជាមួយក្រុមខ្ញុំពីប្រវត្តិខ្លះៗក្នុងសម័យដែលគ្រប់គ្រងដោយខ្មែរក្រហម ។ ទឹកមុខដែលបានញញឹមញញែម រាក់ទាក់ ក៏ក្លាយទៅជាស្រពោនមួយរំពេចបន្ទាប់ពីរឿងរ៉ាវត្រូវបានរំឭកឡើងវិញ ។

១) ភូមិតាកេត (មន្ទីរសន្តិសុខ និងកន្លែងសម្លាប់)

លេខកូដភូមិសាស្ត្រៈ ១៨១០០៥

រយៈកំពស់ៈ **11º 25' 40: 70"**

រយៈទទឹងៈ **105º 30' 26: 96"**

ទីតាំងមន្ទីរសន្តិសុខមួយបានត្រូវប្រាប់ឈ្មោះថាជា "មន្ទីរឃុំឃាំងភូមិតាកេត" ។ ភូមិតាកេត គ្រាន់តែជាអតីតភូមិចាស់មួយដែលគ្មានមនុស្សរស់នៅនាពេលបច្ចុប្បន្ននេះ ។ ក្នុងចម្ងាយដីប្រមាណ៣០០ម៉ែត្រពីផ្ទះអ្នកស្រុកភូមិជ្រៃលើងប៉ែកខាងត្បូងឈៀងខាងកើត គឺជាមន្ទីរឃុំឃាំងភូមិតាកេត ។ រឿងរ៉ាវនៃទីតាំងមន្ទីរសន្តិសុខនេះ បានត្រូវអធិប្បាយប្រាប់ពី យ៉ុន ហ៊ាង ថានៅដើមឆ្នាំ១៩៧៤ មានកងសន្តិសុខប្រមាណពីរ-បីនាក់ បានដើរកាត់ភូមិជ្រៃលើងចុះឡើងៗ ហើយក៏សម្រេចជ្រើសរើសយកទីទួលមួយកន្លែងក្នុងភូមិតាកេតធ្វើជាមន្ទីរឃុំឃាំងតែម្តង ។ ហ៊ាង មានការងឿងឆ្ងល់យ៉ាងខ្លាំងក្រោយពីហេតុការណ៍បានត្រូវលេចឡើង ។ មិនយូរប៉ុន្មានស្រាប់តែគាត់សង្កេតឃើញមានការដឹកជញ្ជូនទាហានឈ្លើយសឹកនៃរបបសាធារណរដ្ឋខ្មែរចូលទៅកាន់មន្ទីរនោះយ៉ាងស្ងៀមស្ងាត់បំផុត ។ តំបន់រំដោះនៅឃុំពានរោង បានក្លាយបន្តិចម្តងៗទៅកាន់ការត្រួតត្រាយ៉ាងពេញលក្ខណៈពីសំណាក់ខ្មែរក្រហម ។ ខែមេសា ឆ្នាំ១៩៧៥ ដែលជាថ្ងៃជ័យជំនះដ៏ធំបំផុតសម្រាប់ការធ្វើបដិវត្តន៍ដំបូងបង្អស់របស់ខ្មែរក្រហម បានក្លាយជាការសម្លាប់មនុស្សយ៉ាងរង្គាលនៅពាសពេញស្រុកព្រៃវែង ខេត្តព្រៃវែង ។ ជនរងគ្រោះដែលជាទាហាននៃរបបសាធារណរដ្ឋលន់ណុលជាច្រើននាក់បានត្រូវបណ្តើរចូលទៅក្នុងគេហដ្ឋានដែលមានជញ្ជាំងបូកដី និងដំបូលប្រក់សង្កសីចំនួនពីរផ្សេង ។ គេហដ្ឋានទាំងពីរនោះហើយ គឺជាមន្ទីរឃុំឃាំងភូមិតាកេត ។ អ្នកទោសតម្រូវឲ្យដាក់ខ្នោះឈើជារៀងរាល់ពេលដែលមិនចេញទៅធ្វើការនៅខាងក្រៅ ។ ការធ្វើទារុណកម្មបានធ្វើឡើងនៅពេលសួរចម្លើយ ។

យ៉ុន ហ៊ាង គឺជាអ្នកថែរក្សាក្របីជាង២០០ក្បាលនៅក្នុងសហករណ៍ភូមិជ្រៃលើង ហើយក៏ជាអ្នកដែលបានឃើញហេតុការណ៍ធ្វើទារុណកម្មទៅលើអ្នកទោសដោយផ្ទាល់ភ្នែកដែរ ។ ហ៊ាង

បានបញ្ជាក់ថាអ្នកទោសទាំងអស់

គឺជាឈ្លើយសឹកទាហាននៃរបបសាធារណរដ្ឋខ្មែរដែលបានចាប់ក្នុងទឹកដីខេត្តព្រៃវែង ។ ក្នុងចំណោមឈ្លើយសឹកទាំងអស់ មានឈ្លើយសឹកប្រមាណ២០០នាក់បានត្រូវសម្លាប់នៅក្នុងបរិវេណមន្ទីរឃុំឃាំងភូមិតាកេតតែក្នុងរយៈពេលប្រមាណមួយឆ្នាំក្រោយថ្ងៃរំដោះ១៧ មេសា ។ ចំណែកមួយចំនួនទៀតបានត្រូវនាំខ្លួនទៅកាន់មន្ទីរសន្តិសុខមួយទៀតឈ្មោះថា “មន្ទីរសន្តិសុខតំបន់២៤ទួលកគោ” បន្ទាប់ពីមន្ទីរឃុំឃាំងភូមិតាកេតត្រូវរំលាយចោលនៅក្នុងអំឡុងឆ្នាំ១៩៧៦ ។ ចំពោះបញ្ហាទាក់ទងនឹងការសម្លាប់ឈ្លើយសឹកសង្គ្រាមនេះ បានត្រូវ ហ៊ីង រាយការណ៍ប្រាប់ថាមកពីភាពខ្ជិលច្រអូសរបស់ពួកគេ(ឈ្លើយសឹក) បូករួមទាំងភាពទម្រន់នឹងការផារផង ។

រណ្តៅពីរ-បីដែលជីកដោយកងសន្តិសុខខ្មែរក្រហម បាយក្លាយទៅជារណ្តៅកប់សាកសពឈ្លើយសឹកដែលជាទាហានប្រឆាំងនៃរបបលន់ណុល ហើយរហូតមកដល់បច្ចុប្បន្ននេះ ក៏នៅតែមានស្លាកស្នាមខ្លះៗបន្សល់ទុកសម្រាប់ជាការប្រាប់ពីការសម្លាប់មនុស្សនាសម័យនោះដែរ ។ ហ៊ីង បានប្រាប់ថា ការសម្លាប់បានប្រព្រឹត្តិទៅក្នុងស្ថានភាពស្ងាត់ស្ងៀមបំផុត ព្រោះថាការសម្លាប់បានចាប់ផ្តើមអនុវត្តនាពេលយប់ និងមិនប្រើកាំភ្លើងជាឧបករណ៍សម្លាប់ឡើយ ។ ព្រនង់ និងដែកភ្លៅរទេះគឺជាឧបករណ៍សំខាន់ដែលមិនអាចអត់បាន ។ របនាសម្ពន្ធ័នានាក្នុងការគ្រប់ មន្ទីរឃុំឃាំងភូមិតាកេត មិនត្រូវបាននរណាម្នាក់ដឹងច្បាស់លាស់ឡើយក្រៅពីពាក្យនិយាយដូចៗគ្នាថា “គ្មានកា គ្រប់គ្រងច្បាស់លាស់ឡើយសម្រាប់មន្ទីរឃុំឃាំងភូមតាកេតនេះ ។ សន្តិសុខម្នាក់អាចគ្រប់គ្រងមន្ទីរនេះបានបី ឬ បួនថ្ងៃប៉ុណ្ណោះ ហើយក៏ត្រូវផ្លាស់ចេញទៅដោយជំនួសអ្នកថ្មីមកទៀត” ។ ការអនុវត្តផែនការនេះ គឺបានធ្វើរហូតដល់មន្ទីរឃុំឃាំងត្រូវបានបំបែក និងបញ្ចប់បេសកកម្មរបស់ខ្លួននៅក្នុងអំឡុងឆ្នាំ១៩៧៦ ។

២) ទួលកគោ (មន្ទីរសន្តិសុខ និងកន្លែងសម្លាប់)

លេខកូដភូមិសាស្រ្តៈ ១៨១០០៦

រយៈកំពស់ៈ **11º 26' 21: 24"**

រយៈទទឹងៈ **105º 30' 51: 25"**

ការបែកបាក់សាមគ្គីភាពផ្ទៃក្នុងរបស់ខ្មែរក្រហម បានធ្វើឲ្យជីវិតប្រជាជនកាន់តែមានការស្លាប់ច្រើនទ្វេរដងនៅក្នុងអំឡុងឆ្នាំ១៩៧៨ ។ ភូមិភាគបូព៌ា ដែលមានខេត្តស្វាយរៀង ព្រៃវែង និងកំពង់ចាមគឺជាចំណុចក្តៅនៃការសម្លាប់រង្គាលនេះ ។

មន្ទីរសន្តិសុខមួយកន្លែងដែលខ្មែរក្រហមបង្កើតឡើងជាមន្ទីរសន្តិសុខតំបន់២៤ បានដំណើរការអស់រយៈពេលជិតមួយអាណត្តិនៃការការកាន់ក្តាប់នៃរបបកម្ពុជាប្រជាធិបតេយ្យ ។ មន្ទីរនេះ ស្ថិតនៅក្នុងភូមិជ្រៃលើង ឃុំពានរោង ស្រុកព្រៃវែង ខេត្តព្រៃវែង ។ នៅឆ្នាំ១៩៧៣ មន្ទីរសន្តិសុខនេះ បានចាប់បដិសន្ធិឡើងក្នុងបំណងឃុំឃាំងទាហានឈ្លើយសឹកនៃរបបសាធារណរដ្ឋខ្មែរដែលត្រូវបានចាប់ខ្លួន ហើយត្រូវបង្ខំឲ្យបញ្ចប់អាណត្តិរបស់ខ្លួននៅចុងឆ្នាំ១៩៧៨ ដោយបានពាំនាំទៅជាមួយនូវជីវិតប្រជាជនស្លូតត្រង់ ទាហាន និងកុមារតូចៗយ៉ាងច្រើន ។ ធឹម ធួន អាយុ៥២ឆ្នាំ, យ៉ុន ហ៊ាង មេភូមិជ្រៃលើង, ឈុន យ៉េង អាយុ៦៥ឆាំ, អ្នកទាំងបីមានទីលំនៅបច្ចុប្បន្ននៅភូមិជ្រៃលើង ឃុំពានរោង ស្រុកព្រៃវែង បានរាយការណ៍ប្រាប់ពីមន្ទីរសន្តិសុខតំបន់២៤ថា កគោគឺជាទួលមួយដែលស្ថិតនៅឆ្ងាយប្រហែលមួយគីឡូម៉ែត្រកន្លះពីភូមិអ្នកស្រុកប៉ែកខាងជើង ។ នៅឆ្នាំ១៩៧៣ ទួលនេះបានត្រូវជ្រើសរើសធ្វើមន្ទីរឃុំឃាំងសម្រាប់តំបន់២៤ទាំងមូល ។ ដើមឈើធំៗ ខ្ពស់ៗជាច្រើនគឺជារបងយ៉ាងមាំ និងរិតតែធ្វើឲ្យមន្ទីរនេះក្លាយជាមន្ទីរសម្ងាត់បំផុតរបស់ខ្មែរក្រហមក្នុងទឹកដីរំដោះ ។ ឈ្លើយសឹកទាហានជាច្រើន បានត្រូវនាំខ្លួនចូលទៅកាន់មន្ទីរកគោកាលពីចន្លោះឆ្នាំ១៩៧៣និង៧៤ ។ លុះដល់ឆ្នាំ១៩៧៥ មន្ទីរនេះត្រូវវែកមុខមាត់បង្ហាញគេឯងគ្រប់គ្នាថាជាមន្ទីរសន្តិសុខតំបន់២៤យ៉ាងពេញលក្ខណៈ ដែលមានការកាន់ក្តាប់ទៅដោយកម្មាភិបាលធំៗចំនួនបីនាក់គឺ វ៉ាត (សព្វថ្ងៃរស់នៅអណ្តូងថ្ម ឃុំពានរោង), សយ (ងាប់) និង កុយ ដែលជាឃាតករដ៏សាហាវម្នាក់ក្នុងចំណោមបីនាក់ (សព្វថ្ងៃរស់នៅខេត្តសៀមរាប) ។ ក្រោយថ្ងៃរំដោះ១៧មេសា ប្រជាជនជម្លៀសទាំងហ្វូងៗបានប្រជ្រៀតគ្នាដណ្តើមទីស្នាក់អាស្រ័យនៅក្នុងអាគារដែលមានជញ្ជាំងបូកដីចំនួន៤ខ្នងដែលអាគារនិមួយៗមានទំហំទទឹង៥ម៉ែត្រ និងបណ្តោយ៤០ម៉ែត្រ ។ អ្នកទោសទាំងឡាយត្រូវស្ថិតនៅឡូកឡំគ្នារវាងឈ្លើយសឹកទាហាន ប្រជាជនជម្លៀស និងអ្នកមូលដ្ឋានមួយចំនួនដែលបានចាប់បញ្ជូនមកដោយសារតែបានប្រព្រឹត្តិខុសនឹងវិន័យរបស់អង្គការដូចជាការលួចនេះលួចនេះ និងខុសសីលធម៌ ។ ការងារធ្ងន់ៗជាច្រើនបានធ្លាក់ទៅលើប្រភេទអ្នកទោសជាទាហានឈ្លើយសឹក និងប្រជាជនជម្លៀស ។ អ្នកទោសណាដែលមិនអាចធ្វើការងារតទៅទៀតបាន ត្រូវយកទៅសម្លាប់ចោល ។ ការអប់រំណែនាំផ្សេងៗ បានត្រូវធ្វើឡើងតែជុំវិញការងារធ្វើស្រែ និងលត់ដំខ្លួនឲ្យក្លាយទៅជាមនុស្សដែលជាទំនុកចិត្តនៃបក្ស ។

ចាប់តាំងពីឆ្នាំ១៩៧៧មក ភូមិភាគបូព៌ាទាំងមូល បានត្រូវរង្គោះរង្គើដោយសារតែសោភឹមក្បត់ ។ រចនាសម្ពន្ធ័ការងារផ្សេងៗ ក៏ត្រូវប្រេះស្រាំស្ទើរគ្មានសល់ ។ កម្មាភិបាលខាងបក្សពួកសោភឹម បានរត់ភៀសខ្លួន និងត្រូវសម្លាប់ស្ទើរអស់ ។ ឯខ្លះទៀតត្រូវចាប់បញ្ជូនខ្លួនបញ្ចូលមកក្នុងមន្ទីរសន្តិសុខតំបន់២៤ ដើម្បីជម្រិតយក

ចម្លើយ រួចទើបសម្លាប់ចោលពេលក្រោយ ។ សម្តីរបស់ ឈុន យ៉េង ថាក្នុងចន្លោះឆ្នាំ១៩៧៧និង៧៨នេះ ទាំងប្រជាជនថ្មី ប្រជាជនមូលដ្ឋាន ទាហានឈ្លើយសឹក និងកម្មាភិបាលខ្មែរក្រហមខាងភូមិភាគបូព៌ា បានត្រូវប្រមូលយកទៅសម្លាប់យ៉ាងច្រើនអនេកនៅទីតាំងសម្លាប់ទួលគ្រៀមគរ (ទួលក្រាំងគរ)[1] ។ ធឹម ធួន ជាប្រជាពលរដ្ឋរស់នៅភូមិជ្រៃលើង ឃុំពានរោង បានរាយការណ៍ថា នៅក្នុងបរិវេណមន្ទីរសន្តិសុខតំបន់២៤នេះ មានអណ្តូងទឹកចំនួនពីរដែលជាអណ្តូងទឹកជីកដោយកម្លាំងទាហានឈ្លើយសឹកកាលពីអំឡុងឆ្នាំ១៩៧៣ បានត្រូវខ្មែរក្រហមខាងភូមិភាគនិរតីយកធ្វើជារណ្តៅកប់សាកសពទាំងអស់ ។ ធួន ក៏បានបន្តទៀតថា ក្នុងអណ្តូងទាំងពីរនេះ មានកប់សាកសព ប្រមាណ១៥០នាក់ក្នុងនោះ ហើយក្រៅពីនោះនៅមានកប់រាយរង់ខាងក្រោមន្ទីរឃុំឃាំងជាច្រើនទៀត ។ យ៉ុន ហ៊ាង និយាយថាសរុបជនរងគ្រោះដែលបានស្លាប់នៅក្នុងបរិវេណនៃមន្ទីរសន្តិសុខតំបន់២៤មានចំនួនរហូតដល់ទៅជិត៥០០នាក់ ។

ថ្ងៃរំដោះ៧មករាឆ្នាំ១៩៧៩ បានធ្វើឲ្យមន្ទីរសន្តិសុខតំបន់២៤ត្រូវរលាយទៅជាមួយជីវិតប្រជាជនរាប់ពាន់នាក់ ។ អ្នកទោសស្ទើរតែទាំងអស់បានត្រូវនាំយកទៅសម្លាប់ចោលមុនពេលថ្ងៃរំដោះចូលមកដល់ ។ អ្នកគ្រប់គ្រងមន្ទីរនេះ ត្រូវរត់ភៀសខ្លួនដោយមិនអាចបន្លង់បាន ។ យ៉ាត គឺជាអ្នកទោសតែម្នាក់គត់ដែលបានរួចខ្លួនពីការសម្លាប់របស់ខ្មែរក្រហម ហើយដែលបច្ចុប្បន្ន យ៉ាត រស់នៅភូមិសង្កែជ្រុំ ឃុំព្រៃគ្អេស (ភូមិព្រៃខ្វែក ឃុំស្វាយអន្ទរ ស្រុកព្រៃវែង) ។

## ស្រុកពារាំង

ដោយសារផ្លូវទៅកាន់ស្រុកពារាំង ត្រូវកាត់ផ្តាច់ដោយទឹកជំនន់នាឆ្នាំកន្លងទៅ ទើបការធ្វើដំណើរទៅកាន់ស្រុកពារាំងត្រូវខកខាន ។ ស្រុកមុខកំពូល ខេត្តកណ្តាល គឺជាទីកន្លែងដែលក្រុមស្រាវជ្រាវខ្ញុំត្រូវឆ្លងកាត់ ។ ខ្ញុំបានធ្វើដំណើរឆ្លងកាត់កំពង់ចម្លងព្រែកអញ្ចាញ ឆ្ពោះទៅកាន់ស្រុកពារាំងដោយបានឆ្លងកាត់ផ្លូវយ៉ាងវែងឆ្ងាយមួយពីត្រើយម្ខាងព្រែកអញ្ចាញតាមផ្លូវស្ពានព្រះគន្លង ។ ស្ពានបាក់ស្រុតចំនួនបីកន្លែង និងផ្លូវលំបាកក្រហេងក្រហូងបានរារាំងដំណើររបស់ខ្ញុំមិនឲ្យសម្រេចកិច្ចការបានប្រសើរឡើយ ទោះជាខ្ញុំនិងពីរនាក់ទៀតខំស្រូតរូតពីព្រឹកព្រលឹមយ៉ាងណាក៏ដោយ ។ នៅវេលាម៉ោងជិត៩ព្រឹក ទើបការធ្វើដំណើររបស់ខ្ញុំបានទៅដល់សាលាឃុំកំពង់ពពិល ស្រុក

---

[1] សូមអានរបាយការណ៍ខេត្តព្រៃវែងឆ្នាំ១៩៩៥ ត្រង់ទីតាំងសម្លាប់ទួលគ្រៀមគរ ។ ទីតាំងនេះចុះស្រាវជ្រាវដោយក្រុមរបស់ Helen Jarvis.

ពារាំង ដែលមានទីតាំងស្ថិតនៅខាងកើតស្ទឹងកំពង់ពពិល ។ ក្រោយពីការជួបពិភាក្សាគ្នាមួយស្របក់មក លោកមេឃុំកំពង់ពពិល បានរួមដំណើរជាមួយក្រុមស្រាវជ្រាវខ្ញុំឆ្ពោះទៅកាន់ទីតាំងសម្លាប់មួយកន្លែងឈ្មោះថា ស្វាយជ្រុំ ។

១) ស្វាយជ្រុំ (ទីតាំងសម្លាប់)

លេខកូដភូមិសាស្ត្រៈ ១៨០៨០៥

រយៈកំពស់ៈ **11º 39' 52: 78"**

រយៈទទឹងៈ **105º 07' 39: 61"**

ស្វាយជ្រុំ ស្ថិតនៅក្នុងភូមិព្រែកថ្មី ឃុំកំពង់ពពិល ស្រុកពារាំង ខេត្តព្រៃវែង ។ ព្រែកថ្មី ជាឈ្មោះភូមិថ្មីមួយដែលត្រូវបានដាក់ជំនួស«ស្វាយជ្រុំ» ។ កាលពីជំនាន់ខ្មែរក្រហម ស្វាយជ្រុំក៏នៅតែប្រើជាឈ្មោះភូមិដដែល ប៉ុន្តែរហូតមកដល់បច្ចុប្បន្ននេះ ភូមិស្វាយជ្រុំបានរលប់បាត់ពីក្នុងបញ្ជីឈ្មោះភូមិក្នុងចំណោមឃុំកំពង់ពពិលទៀត ដោយ បានបន្សល់ទុកនូវទីតាំងសម្លាប់មនុស្សមួយដែលប្រជាពលរដ្ឋនិយមហៅតាំងពីដើមមកថា ទីតាំងសម្លាប់ស្វាយជ្រុំ ។ ក្នុងរបបដែលគ្រប់គ្រងដោយខ្មែរក្រហម ស្វាយជ្រុំគឺជាតំបន់ញាក់សាច់មួយសម្រាប់ប្រជាជនគ្រប់រូបដែលរស់នៅ ក្នុងស្រុកពារាំងទាំងមូល ។ គ្មាននរណាម្នាក់បានស្គាល់កន្លែងនោះ(ស្វាយជ្រុំ) ច្បាស់លាស់ឡើយ ដោយសារតែការ មិនហ៊ានទៅជិត ។ ប្រជាជនមកពីច្រើនឃុំក្នុងស្រុកពារាំង បានត្រូវបញ្ជូនចូលមកកាន់ទីតាំងសម្លាប់ស្វាយជ្រុំនាឆ្នាំ ១៩៧៨ គឺក្នុងអំឡុងពេលដែលមានការប្រេះស្រាំរវាងខ្មែរក្រហមខាងបូព៌ា និងនិរតី ។ កម្មាភិបាលមួយចំនួនខាងភូមិភាគបូព៌ា បានត្រូវសម្លាប់ដោយក្មេងៗខ្មែរក្រហមខាងភូមិភាគនិរតី ហើយមួយចំនួនទៀតត្រូវរត់គេចខ្លួនពីការតាមចាប់ ។ ខ្លះក្លែងខ្លួនធ្វើជាប្រជាជនធម្មតា ខ្លះទៀតត្រូវរត់ចូលព្រៃជ្រៅៗ ។ ក្មេងៗខ្មែរក្រហមដែលនរណា (និយាយតែប្រជាជននៅឃុំកំពង់ពពិល ស្រុកពារាំង) ក៏ដឹងដែរថាជាខ្មែរដែលនិយាយខ្មែរមិនច្បាស់(រដឹនៗ) ច្រើនជាមនុស្សដែលមានអត្តចរិកសាហាវ ឆេវឆាវ ឃោរឃៅ និងគ្មានដឹងខុសដឹងត្រូវអ្វីទាល់តែសោះនោះបានសម្លាប់មនុស្សដោយឥតញញើតដៃ និងឥតកោតក្រែង ។ គ្រាន់តែក្នុងរយៈពេលជិតមួយឆ្នាំនៃការកាន់កាប់របស់ភូមិភាគនិរតី បានធ្វើឲ្យទីតាំងស្វាយជ្រុំមួយក្លាយទៅជាទីតាំងពិឃាតដែលមិនអាចបំភ្លេចបានពីជម្រៅចិត្តនៃមនុស្សគ្រប់រូបដែលបានហែលឆ្លងកាត់នូវមហាទុក្ខសោកនារបបខ្មែរក្រហម ។ រណ្តៅដូចរន្ធបាយខុម បានដុះដើមរុក្ខជាតិជុំជិតនាពេលបច្ចុប្បន្ននេះ ថ្វីត្បិតតែរណ្តៅទាំងនោះលែងជ្រៅដូចមុនក៏ដោយ ។ ទីតាំងសម្លាប់ស្វាយជ្រុំ មិនបានអនុញ្ញាតិឲ្យនរណាម្នាក់ចូលទៅជិតឡើយ បើពុំដូចនោះទេ ពិតជាត្រូវស្លាប់ដោយសារតែរឹងទទឹងនេះមិនខាន ។ ក្រោយថ្ងៃរំដោះឆ្នាំ១៩៧៩ រណ្តៅទាំងឡាយត្រូវបានគាស់ដោយមិនអាចទប់ស្កាត់បាន ដោយសារតែការស្វះស្វែងរកមាស

ពេជ្រពីប្រជាជនដែលរស់នៅទីនោះ ។ ឆ្អឹងជាច្រើន បានត្រូវគ្រវែងចេញពីអណ្តូងមកលើដីយ៉ាងច្រើន ។ ក្លិនស្អុយ បានជះភាយពេញព្រៃនៃទីតាំងស្វាយជ្រុំ ។ សាកសពខ្លះមិនទាន់រលួយនៅឡើយ សាកសពខ្លះទៀតស្ថិតក្នុងសភាព ហើម និងអាក្រាត ។

ឃិត អប់ អាយុ៧១ឆ្នាំ ជាប្រជាជនរស់នៅភូមិព្រែកថ្មី ឃុំកំពង់ពពិល ស្រុកពារាំង ខេត្តព្រៃវែង បានរៀបរាប់ពីទីតាំងស្វាយជ្រុំនេះប្រាប់ថា កាលពីស្ថិតនៅក្នុងតំបន់រំដោះនាដើមទសវត្សរ៍ទី៧០ ស្វាយជ្រុំនេះគឺជារោងបាយ និងមន្ទីរពេទ្យប្រចាំឃុំកំពង់ពពិល ។ កាលនោះ នរណាចង់ចេញចូលគឺបានស្រេចតែចិត្ត ។ ប៉ុន្តែចាប់តាំងពីឆ្នាំ១៩៧៨មក តំបន់នេះបានក្លាយទៅជាតំបន់ហាមឃាត់ និងប្រែក្លាយពីរោងបាយនិងមន្ទីរពេទ្យទៅជាកន្លែងសម្លាប់យ៉ាងសាហាវ ។ កម្មាភិបាលមួយចំនួនបានត្រូវសម្លាប់ និងមួយចំនួនទៀតបានរត់រួច ។ ឈួន ព្រីង អាយុ៥០ឆ្នាំ គឺជាអតីតកម្មាភិបាលពេទ្យខាងបូព៌ា ។ ព្រីង បានរត់ភៀសខ្លួនចូលព្រៃដើម្បីគេចពីការតាមរកចាប់ខ្លួនរបស់ខ្មែរក្រហមខាងនិរតី ។ បច្ចុប្បន្ន ព្រីង ជាមេឃុំកំពង់ពពិល ស្រុកពារាំង ។ ព្រីង បានប្រាប់ពីមុខងាររបស់គាត់កាលពីធ្វើពេទ្យសម័យខ្មែរក្រហមថា មាននាទីទទួលព្យាបាលតែប្រជាជន១៧មេសាប៉ុណ្ណោះ ព្រោះជាពេទ្យដែលមិនសូវចេះអី ។ ចំណែកប្រជាជនមូលដ្ឋាន និងកម្មាភិបាលរបស់ខ្មែរក្រហមត្រូវទៅព្យាបាលនៅមន្ទីរពេទ្យតំបន់ដែលមានគ្រូពេទ្យជំនាញជាច្រើននាក់ ។ ព្រីង បានឈប់ពីធ្វើពេទ្យ ដោយសារតែខ្លួនត្រូវខ្មែរក្រហមខាងនិរតីតាមរកចាប់ខ្លួនយកទៅសម្លាប់ចោល ។

ទីតាំងស្វាយជ្រុំ បានធ្វើឲ្យមនុស្សប្រមាណជិត១០០០នាក់ត្រូវស្លាប់ដោយការធ្វើទារុណកម្ម និងសម្លាប់នៅក្នុងរណ្តៅជាង៣០ដែលស្ថិតក្នុងបរិវេណដីប្រមាណជិត៣ហិកតា ។ ឃុត អប់ បានបញ្ជាក់ថា ចំពោះជនរងគ្រោះដែលជានារីភេទ ត្រូវទទួលរងនូវការចាប់រំលោភសិនមុនពេលសម្លាប់ ។ ការសម្លាប់មនុស្សនៅស្វាយជ្រុំបានបែងចែកជាពីរលើកគឺ លើកទីមួយមានសម្លាប់កម្មាភិបាលដែលជាបក្សពួកខាងសោ ភឹម និងលើកទីពីរគឺជាប្រជាជនធម្មតាដែលបានចាប់មកពីឃុំជាច្រើននៅក្នុងស្រុកពារាំងទាំងមូល ។ ឃុត អប់ បានប្រាប់ពីមនុស្សដែលបានសម្លាប់ជនរងគ្រោះទាំងអស់នៅទីតាំងស្វាយជ្រុំថា ជាកងទ័ពឈ្លើមរបស់ខ្មែរក្រហម ។ ជនរងគ្រោះដែលស្ថិតនៅក្នុងបន្ទប់តូចៗជាច្រើននៃអាគារធ្វើពីឈើមួយដែលជាអតីតមន្ទីរពេទ្យ និងរោងបាយ បានត្រូវនាំយកទៅសម្លាប់ជារៀងរាល់ថ្ងៃ ។ ឯការបញ្ជូនមនុស្សថ្មីៗចូលមក ក៏មានជារៀងរាល់ថ្ងៃដែរ ។

៧) វត្តក្រាំងពិសី (មន្ទីរសន្តិសុខ និងទីតាំងសម្លាប់)

លេខកូដភូមិសាស្ត្រៈ ១៤០៨០៦

រយៈកំពស់ៈ **11º 39' 12: 73"**

*រយៈទទឹងៈ* **105º 11' 50: 89"**

ឆ្អឹងសាកសពមួយពាំនូកធំ បានត្រូវធ្វើពិធីបូជាក្នុងថ្ងៃតែមួយនឹងថ្ងៃដារឆ្លងព្រះវិហារដែលទើបសាងសង់ថ្មី នៅវត្តក្រាំងពិសី ។ វត្តនេះស្ថិតនៅក្នុងភូមិពាមអំពិល ឃុំរាប ស្រុកពារាំង ខេត្តព្រៃវែង ។ កាលសម័យខ្មែរក្រហមកាន់អំណាច វត្តក្រាំងពិសី គឺជាមន្ទីរឃុំឃាំងមួយដែលមានអ្នកទោសរាប់ម៉ឺននាក់ ។ វត្តក្រាំងពិសី គឺជាកន្លែងទី២បន្ទាប់ពីមន្ទីរសន្តិសុខធំនៅវិទ្យាល័យញ៉ឹម វណ្ណដា ពារាំង សព្វថ្ងៃនេះ ។ មន្ទីរសន្តិសុខក្រោយនេះ បានបង្កើតឡើងនៅឆ្នាំ១៩៧៧ ហើយមានតួនាទីទទួលខុសត្រូវចំពោះអ្នកទោសដែលជាប់ទោសស្រាលៗ ។ ទោះជាយ៉ាងនេះក៏ដោយ នៅចុងឆ្នាំ១៩៧៧ឈានចូលឆ្នាំ១៩៧៨ អ្នកទោសទាំងនោះ ត្រូវយកទៅសម្លាប់ចោលទាំងអស់នៅទីវាលមួយដែលស្ថិតនៅចម្ងាយប្រហែល៥០ម៉ែត្រពីបរិវេណវត្តក្រាំងពិសី ។ ការធ្វើទារុណកម្មនានាបានត្រូវចាប់អនុវត្តឡើងនៅក្នុងរូងក្រោមដីមួយដែលមានឧបករណ៍សម្រាប់សួរចម្លើយដូចជាពាងដាក់ទឹកសាប៊ូ តុ និងឧបករណ៍ផ្សេងទៀត ។ អ្នកទោសដែលបានឆ្លងកាត់ការសួរចម្លើយហើយ ត្រូវនាំយកទៅសម្លាប់ចោលដោយមិនអាចជៀសផុត ។ ចរាចរណ៍នានាត្រូវបានផ្អាកចាប់តាំងពីចុងឆ្នាំ១៩៧៧មក ដោយសារតែពេលនោះខ្មែរក្រហមដែលមកពីភូមិភាគនិរតីបានចូលមកកាន់កាប់ជំនួសម្តង ។

ជិន សាមឿន អាយុ៥៦ឆ្នាំ ជាគ្រូបង្រៀននៅសាលាបឋមសិក្សាវត្តក្រាំងពីសីបានរៀបរាប់ថា «ការធ្វើទារុណកម្មលើអ្នកទោសគឺមានភាពសាហាវយង់ឃ្នងណាស់» ។ ចំណែកឯមន្ទីរឃុំឃាំងវិញ ខ្មែរក្រហមបានបង្កើតឲ្យមានគុកងងិតដែលស្ថិតនៅជាន់ក្រោមគុកធម្មតានៃសាលាឆាន់វត្តក្រាំងពិសីតែមួយ ។ នៅមានគុកមួយទៀតដែល សាមឿន ហៅថា «គុកឥតជញ្ជាំង» ស្ថិតនៅប៉ែកខាងក្រោបរិវេណវត្តតែប្រមាណ៣០ម៉ែត្រប៉ុណ្ណោះ មានអ្នកទោសជាច្រើនជាប់នៅទីនោះ ជាមួយនឹងខ្នោះដាក់ជើងជាប់ទាំងសង្វាង ។ គុកនេះ គ្មានជញ្ជាំងទេ មានតែរនាបឫស្សីតូចៗសម្រាប់ដាក់អ្នកទោសប៉ុណ្ណោះ ។

ហែម រៀម អាយុ៧១ឆ្នាំ រស់នៅភូមិពាមអំពិល ឃុំរាប ស្រុកពារាំង បានប្រាប់ថា គុកនៅវត្តក្រាំងពិសីនេះ គឺជាសាខារបស់មន្ទីរសន្តិសុខស្រុកពារាំងដែលមានចម្ងាយប្រហែល៤គីឡូម៉ែត្រពីគ្នា ។ រៀម បានប្រាប់ទៀតថា ចំពោះអ្នកដែលមានបញ្ហាបន្តិចបន្តួចពីរឿងលួចនេះលួចនោះ ក៏ត្រូវចាប់បញ្ជូនមកកាន់មន្ទីរនេះដែរ ហើយមួយចំនួននៃអ្នកទាំងនោះ ត្រូវបានសម្លាប់ និងមួយចំនួនទៀតបានរួចខ្លួនរហូតដល់សព្វថ្ងៃ ។ មូលហេតុនេះបានត្រូវ រៀម រាយការណ៍ថាមកពីដល់ថ្ងៃរំដោះឆ្នាំ១៩៧៩ ។ រៀម ប្រាប់ទៀតថា មានអ្នកទោសច្រើននាក់បានរត់រួចខ្លួនពេលដែលស្ថានភាពកំពុងវឹកវរ ។ ឆ្នាំងបបរត្រូវជះពាសពេញទីធ្លាគុក ដើម្បីឲ្យអ្នកទោសដែលជាប់ខ្នោះលិតនៅផ្ទាល់ឥដ្ឋ ។ កម្មាភិបាលដែលនៅប្រចាំការនៅគុកនេះ ត្រូវរត់ចោលតួនាទីរបស់ខ្លួនដើម្បីគេចពីការ

តាមសម្លាប់នៃគ្រួសារជនរងគ្រោះ ។ រណ្តៅមួយចំនួនបានត្រូវគាស់ ឆែកឆេររកមាសពេជ្រ និងវត្ថុមានតម្លៃផ្សេងទៀតពីខ្លួនរបស់សាកសព ។ ឆ្អឹង និងលលាដ៍ក្បាលសាកសព បានត្រូវបោះគរជាច្រើនពំនូកនៅក្បែរមាត់រណ្តៅ ។ ពេលបន្ទាប់ អដ្ឋិធាតុទាំងនោះ បានត្រឹមតែប្រមូលមកដាក់គរតែមួយពំនូកនៅពីក្រោយព្រះវិហារ ។ លុះនៅពេលដែលព្រះវិហារថ្មី បានសាងសង់ជិតហើយនោះ ប្រជាពលរដ្ឋចំណុះជើងវត្តបានមូលមតិគ្នាកម្ទេចឆ្អឹងទាំងនោះចោលរួមជាមួយការធ្វើពិធីបុណ្យដារឆ្លងព្រះវិហារថ្មីផង ។ ទោះជាយ៉ាងនេះក៏ដោយ ក៏ ហែម រៀម បាននិយាយថា «បើចង់បានឆ្អឹង ដើរគាស់តែបន្តិចបានភ្លាម» ។

សោ ឈាង អាយុ៥០ឆ្នាំ ជាអ្នកដែលបានឃើញហេតុការណ៍ផ្ទាល់ភ្នែកច្រើនជាងគេ បានប៉ាន់ស្មានចំនួនសាកសពដែលបានស្លាប់នៅក្នុងបរិវេណវត្តក្រាំងពិសីថាមានចំនួនពី៣-៤ម៉ឺននាក់ ។ ចំណែករណ្តៅវិញ គឺមិនអាចប៉ាន់ស្មានបានឡើយ ព្រោះ ឈាង ថាមានចំនួនច្រើនពេក ។

### ៣) វិទ្យាល័យញ៉ឹម វណ្ណដា ពារាំង (មន្ទីរសន្តិសុខ និងទីតាំងសម្លាប់)

*លេខកូដភូមិសាស្ត្រ៖ ១៨០៨០៧*

*រយៈកំពស់៖* **11º 39' 53: 33"**

*រយៈទទឹង៖* **105º 14' 46: 33"**

មន្ទីរសន្តិសុខមួយកន្លែងបានត្រូវបង្កើតឡើងកាលពីឆ្នាំ១៩៧៥នៅក្នុងបរិវេណវិទ្យាល័យ ញ៉ឹម វណ្ណដា ពារាំង ដែលប្រើប្រាស់ជាមន្ទីរសន្តិសុខប្រចាំស្រុកពារាំង ។ មន្ទីរសន្តិសុខនេះ មានឃុំឃាំងប្រភេទជនរងគ្រោះគ្រប់ប្រភេទ ទាំងទោសធ្ងន់ និងស្រាល ។ មន្ត្រីទាហាននៃរបបសាធារណរដ្ឋខ្មែរមួយចំនួន បានមានវាសនាអាក្រក់ធ្លាក់ខ្លួនមកជាប់នៅក្នុងមន្ទីរឃុំឃាំងស្រុកពារាំងនេះ ក្រោមឡេសចោទប្រកាន់ថាជាអ្នកដែលជាន់និន្នាការនយោបាយក្បត់និងបដិវត្តន៍ ។

កាក់ ហាក់ អាយុ៥០ឆ្នាំ សព្វថ្ងៃជាគ្រូបង្រៀននៅវិទ្យាល័យ ញ៉ឹម វណ្ណដា ពារាំង បានប្រាប់ស្រដៀងគ្នាដែរថា មុនដំបូងខ្មែរក្រហមបានស្រាវជ្រាវរកឈ្មោះមនុស្សដែលធ្លាប់ជាប់និន្នាការនយោបាយពីសង្គមចាស់រួចចាប់បញ្ជូនមកកាន់មន្ទីរសន្តិសុខនេះដើម្បីអប់រំកែប្រែតាមមាគ៌ាបដិវត្តដ៏ភ្លឺស្វាង ។ ការចាប់បញ្ចូលនេះ គឺអនុវត្តតែទៅលើមនុស្សប្រុស ឬប្ដីៗតែប៉ុណ្ណោះ ។ ចំណែកមនុស្សស្រី ឬប្រពន្ធវិញ ត្រូវយកទៅដាក់តាមសហករណ៍ ឬក្រុមសាមគ្គីនានាដែលស្ថិតនៅក្នុងស្រុកពារាំងដែរ ។ ក្រៅពីអ្នកដែលជាប់និន្នាការទៅ នៅមានប្រជាជន១៧មេសា និងអ្នកមូលដ្ឋានខ្លះទៀត បានមកជាប់នៅក្នុងមន្ទីរសន្តិសុខនេះដែរ ។ ហាក់ បានឮផ្ទាល់នឹងត្រចៀកនូវសម្រែកដែលចេញមកពីបន្ទប់សួរចម្លើយ ។ ពីមួយថ្ងៃទៅមួយថ្ងៃ មានជនរងគ្រោះស្លាប់យ៉ាងច្រើនដោយសារតែ

ការវាយស្គរចម្លើយពីសន្តិសុខប្រចាំការនៅក្នុងគុក ។ សាកសពត្រូវអូសយកទៅកប់នៅផ្នែកខាងក្រោយអាគារគុក ដែលមានរណ្តៅធំមួយ និងរណ្តៅតូចៗជាច្រើនទៀតនៅរង់ចាំ ។ ហាក់ ខស្យាហ៍បានឃើញការដឹកអ្នកទោសចូលទៅកាន់មន្ទីរឃុំឃាំងស្រុកដែលភាគច្រើនចាប់មកពីកងចល័ត ។ អ្នកទោសភាគច្រើនបានត្រូវសម្លាប់ និងមួយចំនួនទៀតបានរត់រួចខ្លួន បន្ទាប់ពីមានហេតុការណ៍ថា សោភឹម ក្បត់បដិវត្តន៍ ។ ហាក់ បានអធិប្បាយរឿង នេះថា អ្នកទោសទាំងអស់ និងឆ្មាំគុកបានភ្ញាក់ផ្អើលគ្រប់គ្នានៅពេលឃើញយន្តហោះមួយគ្រឿងបានហោះក្រឡឹងជុំវិញមន្ទីរ សន្តិសុខនេះ ។ គ្រាក់យ៉ាងច្រើនបានត្រូវបាចទម្លាក់ពីលើយន្តហោះ ធ្លាក់ក្រាលពេញដីទាំងក្នុងនិងក្រៅមន្ទីរឃុំ ឃាំង ។ អត្ថន័យនៅក្នុងក្រដាស់នោះ បានបញ្ជាក់ពីមេដឹកនាំភូមិភាគបូព៌ាឈ្មោះ សោភឹម ក្បត់ ហើយត្រូវតាមចាប់ខ្លួនជាបន្ទាន់ ។ មិនយូរប៉ុន្មាន ការកាន់កាប់ថ្មីមួយបានចាប់ផ្តើមឡើងដោយមានការត្រួតត្រាពីខ្មែរក្រហមខាងភូមិភាគនិរតីយ៉ាងពេញទំហឹង ។ ដំណឹងនានាបានត្រូវប្រកាសស្តីពីការតាមរកចាប់ខ្លួនកម្មាភិបាលដែលជាប់ពាក់ព័ន្ធនឹងសោភឹម ។ មន្ទីរសន្តិសុខស្រុក នៅតែមានតួនាទីសំខាន់ដដែលក្នុងការឃុំឃាំងអ្នកទោស ។ លើកនេះ សង្កេតឃើញថាមានអ្នកទោសរិតតែច្រើនលើសដើមបានចូលមកកាន់មន្ទីរនេះ រហូតដល់គ្មានកន្លែងដាក់ ។ សាខានៃមន្ទីរសន្តិសុខនេះ បានត្រូវបង្កើតឡើងនៅវត្តក្រាំងពិសី ។ អ្នកទោសត្រូវបែងចែកជាពីរប្រភេទគឺ ធ្ងន់ និងស្រាល ។ អ្នកទោសស្រាលបានបែងចែកមកកាន់មន្ទីរឃុំឃាំងនៅវត្តក្រាំងពីសី ហើយដែលក្រោយមកត្រូវសម្លាប់ទាំងអស់ ។ ការសម្លាប់នេះក៏ត្រូវធ្វើឡើងដូចគ្នាដែរចំពោះមន្ទីរសន្តិសុខធំរបស់ស្រុកនេះ គឺនៅក្នុងបរិវេណនៃមន្ទីរសន្តិសុខខ្លះ និងមួយចំនួនធំទៀតបានយកទៅសម្លាប់នៅទួលអ្នកតាចិន និងនៅស្ពាយដួច ។

ក្រោយថ្ងៃរំដោះឆ្នាំ១៩៧៩ រណ្តៅមួយចំនួននៅក្នុងបរិវេណវិទ្យាល័យពារាំង បានត្រូវគាស់ ។ អដ្ឋិធាតុទាំងឡាយមិនបានប្រមូលទុកដាក់នៅកន្លែងសមរម្យឡើយ ។ រហូតមកដល់បច្ចុប្បន្ននេះ វិទ្យាល័យពារាំងបានទទួលសិស្សានុសិស្សគ្រប់រូបឲ្យចូលរៀនជារៀងរាល់ឆ្នាំ ។ រឿងរ៉ាវពីអតីតកាលដែលបានកើតមានឡើងនៅក្នុងបរិវេណវិទ្យាល័យនេះ ហាក់បានកប់បាត់ និងឆ្ងាយទៅៗពីអារម្មណ៍នៃមនុស្សគ្រប់រូបដែលជាឪពុកម្តាយរបស់សិស្សានុសិស្សទាំងឡាយ ព្រោះគ្មានកូនសិស្សណាម្នាក់បានដឹងរឿងរ៉ាវនេះឡើយ ។ កាក់ ហាក់ ដែលបច្ចុប្បន្នជាគ្រូបង្រៀននៅវិទ្យាល័យញឹម វណ្ណដា ពារាំង បានប្រាប់ថា គាត់ស្ទើរតែភ្លេចបាត់ទៅហើយនូវរឿងរ៉ាវទាំងនេះ ។ សូម្បីតែការប៉ាន់ស្មានចំនួនជនរងគ្រោះក៏ គាត់ភ្លេចអស់ដែរ ។

៤) ទួលអ្នកតាចិន (ទីតាំងសម្លាប់)

*លេខកូដភូមិសាស្ត្រៈ ១៨០៨០៨*

*រយៈកំពស់ៈ* **11º 39' 48: 70"**

*រយៈទទឹងៈ* **105º 13' 30: 46"**

*ចាប់តាំងពីចុងឆ្នាំ១៩៧៧រហូតមកដល់ចុងឆ្នាំ១៩៧៨ ទួលអ្នកតាចិនគឺជាទីតាំងសម្លាប់មនុស្សយ៉ាងសាហាវមួយនៅក្នុងភូមិស្នាយពល ឃុំរកា ស្រុកពារាំង ខេត្តព្រៃវែង។ កាលពីឆ្នាំ១៩៧៥រហូតមកដល់ចុងឆ្នាំ១៩៧៧ ទីតាំងនេះគឺជាទីស្នាក់ការឃុំ។ លុះដល់មានស្ថានភាពផ្លាស់ប្តូរ ទីស្នាក់ការឃុំក៏ត្រូវតែផ្លាស់ប្តូរទៅនៅឬស្សីជុក វិញ។ ឯកម្មាភិបាលខ្មែរក្រហមដែលធ្លាប់ធ្វើការនៅទីស្នាក់ការនោះ ត្រូវចាប់ខ្លួននិងសម្លាប់ចោលទាំងអស់នៅនឹងកន្លែងដែលខ្លួនធ្លាប់ធ្វើការកាលពីប៉ុន្មានឆ្នាំមុន។ សៅ អាន អាយុ៧០ឆ្នាំ ជាប្រជាពលរដ្ឋរស់នៅភូមិស្នាយពល ឃុំរកា ស្រុកពារាំង បានប្រាប់ថា ឃើញមានភាគច្រើនបំផុតនៃសាកសពគឺជាមនុស្សដែលមានឯកសណ្ឋានខ្មៅ ឯមួយចំនួនទៀតគឺជាមនុស្សដែលមានសម្លៀកបំពាក់រហែករហ៊ែ។ អាន បានសន្និដ្ឋានថា អ្នកដែលមានឯកសណ្ឋានពណ៌ខ្មៅទាំងនោះ គឺជាកម្មាភិបាលខ្មែរក្រហមខាងបក្សពួកសោភឹម។ ការសម្លាប់មនុស្សនៅទីតាំងទួលអ្នកតាចិន បានចាប់ផ្តើមនៅដើមឆ្នាំ១៩៧៨ ដោយខ្មែរក្រហមមកពីភូមិភាគនិរតី។*

*អណ្តូងទឹកចំនួនមួយ និងរណ្តៅធំៗចំនួនពីរ បានត្រូវប្រើសម្រាប់ធ្វើជាកន្លែងដាក់សាកសព។ អាន បាននិយាយប្រាប់ទៀតថា មនុស្សដែលត្រូវយកមកសម្លាប់នៅទីតាំងទួលអ្នកតាចិននេះ គឺបណ្តើរយកមកនាពេលព្រលប់ដោយកងសន្តិសុខដែលប្រចាំការនៅទីស្នាក់ការស្រុក។*
*អ្នកទោសគ្រប់ប្រភេទបានត្រូវបណ្តើរមកទាំងខ្សែៗ កាត់តាមភូមិដែលមានប្រជាជនរស់នៅ។ តាំងពីព្រឹកព្រលឹមរហូតដល់ថ្ងៃរសៀល ទីតាំងទួលអ្នកតាចិនមានសភាពស្ងប់ស្ងាត់ហាក់គ្មានរឿងអ្វីកើតឡើងទាល់តែសោះ។ ផ្ទុយទៅវិញ ទីតាំងនេះក៏មានមនុស្សស្លាប់មិនតិចដែរដោយសារការសម្លាប់ពីពួកខ្មែរក្រហមមកពីភូមិភាគនិរតី។ អាន និយាយថាបានឃើញរឿងរាល់ល្ងាចពេលដែលគាត់បានដើរទៅនេសាទត្រីនៅក្នុងស្ទឹងមួយក្បែរនោះ។*

*ក្រោយឆ្នាំ១៩៧៩ រណ្តៅសាកសពទាំងពីរ និងអណ្តូងទឹកមួយ ត្រូវបានគាស់ឡើង។ ឆ្អឹងទាំងឡាយត្រូវស្ថិតនៅរាយប៉ាយពេលវាលពាសកាល និងគ្មានសណ្តាប់ធ្នាប់។ មួយភាគនៃសាកសពដែលបានស្លាប់ទាំងនោះមិនទាន់រលួយអស់ទាំងស្រុងនៅឡើយទេ។ សម្លៀកបំពាក់នៃសពខ្លះ បានត្រូវស្គាល់យ៉ាងច្បាស់ថាជាគ្រួសារបង ប្អូន សាច់ញាតិនៃអ្នកដែលនៅរស់ ហើយត្រូវបានស្រង់យកទៅធ្វើបុណ្យតាមប្រពៃណី។ ក្រោយការគាស់*

ធ្លឹង ទាំងឡាយមិនត្រូវបានថែរក្សាឡើយ ឯរណ្ដៅទាំងពីរក៏មិនបានលប់ឲ្យជិតវិញដែរ ។ ចំណែកអណ្ដូងទឹកវិញនៅតែ មានភិនភាគដូចដើមដដែល ប៉ុន្ដែអណ្ដូងនេះ រហូតមកដល់សព្វថ្ងៃនៅតែគ្មានមនុស្សប្រើប្រាស់ ។

**ទីតាំងដែលមិនទាន់បានស្រាវជ្រាវៈ**

- ស្នាយដូច ស្ថិតនៅឃុំរកា ស្រុកពារាំង ខេត្តព្រៃវែង ។
- ទួលសោមស្មៃ ស្ថិតនៅក្បែរវត្តត្នោត ឃុំកំពង់ឫស្សី ស្រុកពារាំង ។
- ព្រៃក្រឡាញ់ ស្ថិតនៅក្នុងភូមិព្រៃក្រឡាញ់ធំ ឃុំព្រៃស្រឡិត ស្រុកពារាំង ។

## សន្និដ្ឋាន

ជាលទ្ធផល ក្រុមស្រាវជ្រាវខ្ញុំបានធ្វើការទៅលើទីតាំងចំនួន៦នៃស្រុកចំនួនពីរគឺស្រុកព្រៃវែង និងស្រុកពារាំង ។ ថ្វីត្បិតតែមានបញ្ហាខ្លះៗទៅលើការធ្វើដំណើរ ប៉ុន្ដែលទ្ធផលដែលទទួលបានគឺល្អប្រសើរ ។

ភូមិភាគបូព៌ាបានទទួលរងនូវការគ្រប់គ្រងពីខ្មែរក្រហមពីរបក្ខផ្សេងគ្នា ។ ជីវិតមនុស្សរាប់សែននាក់បានត្រូវសម្លាប់ដោយសារតែការប្រេះស្រាំខាងផ្នែកនយោបាយ ។ ការគ្រប់គ្រងថ្មី មិនដូចការគ្រប់គ្រងចាស់ដែលមានភាពធូរលុងឡើយ ។ ទាំងការងារ ទាំងការហូបចុក ត្រូវរឹតបន្ដឹង ។ កម្មាភិបាលមួយចំនួនបានត្រូវសម្លាប់រួមជាមួយប្រជាជនដែរ ដោយសារតែឡើសរួមដៃក្បត់នឹងអង្គការបដិវត្ដន៍ ។ ទីតាំងវត្តអារាមមួយចំនួន បានត្រូវជ្រើសរើសក្រោយដោយកម្មាភិបាលដែលមកពីភូមិភាគនិរតី យកធ្វើជាទីតាំងសម្លាប់ និងមន្ទីរសន្តិសុខ ដូចជាវត្តក្រាំងពិសីជាដើម ។ ទួលអ្នកតាចិន ក៏ជាកន្លែងថ្មីដែលត្រូវជ្រើសរើសយកធ្វើជាកន្លែងសម្លាប់មនុស្សដែរគឺនៅក្នុងឆ្នាំ១៩៧៨ ។ ចំណែកឯភូមិស្វាយជ្រុំក៏ដូចគ្នាដែរ កាលពីស្ថិតក្នុងតំបន់រំដោះរហូតមកដល់ត្រឹមចុងឆ្នាំ១៩៧៧ គឺជាមន្ទីរពេទ្យ និងរោងបាយ ។ ប៉ុន្ដែលុះមកដល់ដើមឆ្នាំ១៩៧៨ ក៏ក្លាយទៅជាទីតាំងសម្លាប់យ៉ាងធំមួយដែររបស់ខ្មែរក្រហមដែលមកពីភូមិភាគនិរតី ។ ភាពវឹកវរ ចលាចល និងភ័យខ្លាចនានា ត្រូវបានបញ្ចប់នៅដើមឆ្នាំ១៩៧៩ បន្ទាប់ពីការវាយឲ្យបរាជ័យពីកងទ័ពរដ្ឋាភិបាលទៅលើកងទ័ពខ្មែរក្រហមកាលពីថ្ងៃ៧មករា១៩៧៩ ។ ទឹកចិត្ត និងអារម្មណ៍របស់ប្រជាពលរដ្ឋម្នាក់ៗ សុទ្ធតែចង់ឲ្យមានការសងសឹកវិញភ្លាមៗបន្ទាប់ពីការទទួលបានជ័យជំនះ ប៉ុន្ដែរហូតមកដល់បច្ចុប្បន្ន ការសងសឹកហាក់ស្ថិតនៅឆ្ងាយទៅៗពីជម្រៅចិត្តនៃប្រជាជនគ្រប់រូប ។ ទោះជាយ៉ាងនេះក្ដី ក៏ពួកគាត់(ប្រជាពលរដ្ឋ) នៅតែចង់ឲ្យមានតុលាការមួយដើម្បីកាត់ទោសមេខ្លោងធំៗដែលជាអ្នកផ្ដួច

ផ្ដើមនូវគំនិតសម្លាប់មនុស្ស ។ ប្រធានភូមិជ្រៃរលើងបាននិយាយថា គាត់ចង់បរិយាយរឿងរ៉ាវសម័យខ្មែរក្រហម ប្រាប់គេឯងខ្លាំងណាស់ ព្រោះវាអាចជួយបន្ធូរនូវការឈឺចាប់អស់មួយកំរិតពីអារម្មណ៍របស់គាត់ ។

---